# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២០ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីជំរុញ ត្រួតពិនិត្យ និងតម្រង់ទិសការងារ បូជនីយដ្ឋានចងចាំនៃកម្ពុជាពីឧក្រិដ្ឋកម្មមកសន្តិភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៤/៩៥៤ ថ្ងៃទី៧ ខែសីហា ២០២៤ ស្តីពីការបង្កើតគណៈកម្មការជាតិយូណេស្កូកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៥/៣០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៥ ស្តីពីការបង្កើតបូជនីយដ្ឋានចងចាំនៃកម្ពុជាពីឧក្រិដ្ឋកម្មមកសន្តិភាព
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**ប្រការ១ ._**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីជំរុញ ត្រួតពិនិត្យ និងតម្រង់ទិសការងារបូជនីយដ្ឋានចងចាំនៃកម្ពុជាពីឧក្រិដ្ឋកម្មមកសន្តិភាព ដែលមានសមាសភាពដូចខាងក្រោម៖

- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ប្រធាន
- តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អនុប្រធាន
- តំណាងក្រសួងមហាផ្ទៃ អនុប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- តំណាងក្រសួងទេសចរណ៍ សមាជិក
- អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ សមាជិក
- អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង សមាជិក
- អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ សមាជិក
- ប្រធានសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង សមាជិក
- ប្រធានមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក សមាជិក។

គណៈកម្មការអន្តរក្រសួងនេះ អាចមានសមាសភាពបន្ថែមជាអនុប្រធានឬសមាជិក ដែលជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់។ សមាសភាពបន្ថែមត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

សមាសភាពជាក់ស្តែងរបស់គណៈកម្មការអន្តរក្រសួងនេះ ត្រូវទទួលស្គាល់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការអន្តរក្រសួងនេះ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមី។

**ប្រការ២ ._**

គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចដូចខាងក្រោម៖

- ជំរុញយន្តការការពារស្លាកស្នាមប្រវត្តិសាស្ត្រ ដែលគាំទ្រដល់គុណតម្លៃជាសកលនៃបូជនីយដ្ឋានចងចាំនៃកម្ពុជាពីឧក្រិដ្ឋកម្មមកសន្តិភាព
- ពិនិត្យនិងសម្រេចលើគោលនយោបាយនិងផែនការយុទ្ធសាស្ត្រលើការអភិរក្ស ការស្រាវជ្រាវ ការអប់រំ និងការផ្សព្វផ្សាយពីបូជនីយដ្ឋានចងចាំនៃកម្ពុជាពីឧក្រិដ្ឋកម្មមកសន្តិភាព
- ជំរុញយន្តការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រង ការការពារ ការថែរក្សា ការស្រាវជ្រាវ ការអប់រំ និងការផ្សព្វផ្សាយពីបូជនីយដ្ឋានចងចាំនៃកម្ពុជាពីឧក្រិដ្ឋកម្មមកសន្តិភាព
- ពិនិត្យនិងសម្រេចលើក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង ថែរក្សា និងការពារបូជនីយដ្ឋានចងចាំនៃកម្ពុជាពីឧក្រិដ្ឋកម្មមកសន្តិភាព រួមទាំងទីតាំងប្រវត្តិសាស្ត្រផ្សេងទៀតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ
- ពិនិត្យនិងផ្តល់យោបល់លើការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទនិងនីតិវិធីនៃការគ្រប់គ្រងការពារ ថែរក្សា អភិរក្ស និងអភិវឌ្ឍបូជនីយដ្ឋានចងចាំនៃកម្ពុជាពីឧក្រិដ្ឋកម្មមកសន្តិភាព
- ពិនិត្យនិងសម្រេចលើរបាយការណ៍លទ្ធផលការងារប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។



95

**ប្រការ៣ .-**

គណៈកម្មការអន្តរក្រសួងនេះ អាចកោះប្រជុំតាមការចាំបាច់។

អនុប្រធាននិងសមាជិកគណៈកម្មការអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានណាម្នាក់តាមការប្រគល់សិទ្ធិពីប្រធាន។

ក្នុងករណីអវត្តមានឬករណីចាំបាច់ ប្រធានគណៈកម្មការអន្តរក្រសួងនេះអាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**ប្រការ៤ .-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងឥស្សរជន តំណាងអាជ្ញាធរមូលដ្ឋាន ឬមន្ត្រីជំនាញចូលរួមប្រជុំតាមការចាំបាច់។

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិអញ្ជើញដៃគូអភិវឌ្ឍ វិស័យឯកជន ទីប្រឹក្សា ឬជំនាញការជាតិ និងអន្តរជាតិចូលរួមប្រជុំពិគ្រោះយោបល់តាមការចាំបាច់។

**ប្រការ៥ .-**

គណៈកម្មការអន្តរក្រសួងនេះ មានសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ជាលេខាធិការដ្ឋាន។

**ប្រការ៦ .-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើត្រារបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ប្រការ៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៩រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ